**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន មេតថេក (ខេមបូឌា) ខប លីមីតធីត**

# កិច្ចព្រមព្រៀងស្តីពី

ការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិក

នាថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ២០២១ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក ក្រុមហ៊ុនមេត ថេក (ខេមបូឌា) ខប លីមីតធីតបានធ្វើការពិភាក្សាជាមួយប្រតិភូបុគ្គលិកប្រចាំអាគារទូប៉ាង១និងទូប៉ាងថ្មី ស្តីពីការព្យួរកិច្ចសន្យាការងារជាបណ្តោះអាសន្នចំពោះអាគាទាំងពីរខាងលើនេះដោយសារតែការបញ្ជាទិញពីភ្ញៀវមានការធ្លាក់ចុះយ៉ាងគំហុក និងរួមផ្សំនិងភាពយឺតយាវនៃការមកដល់របស់វត្ថុធាតុដើមសំរាប់សង្វាក់ផលិតកម្ម ជាហេតុទើបនិយោជកគិតគូរពីការព្យួកិច្ចសន្យាការងារមួយរយះដើម្បីបញ្ចៀសពីការខាតបង់ធ្ងន់ធ្ងរណាមួយដែលអាចឈានដល់ការបញ្ឈប់កម្មករក្នុងទ្រង់ទ្រាយធំ។ ដូច្នេះក្រុមហ៊ុនស្នើសុំព្យួរកិច្ចសន្យាការងារនិយោជិកកម្មករចំនួន១៥២២នាក់ រយះពេល៣សប្តាហ៍គិចចាប់ពីថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ២០២១ ដល់ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០២១ ។ បន្ទាប់ពីបានធ្វើការពិភាក្សាគ្នារួចមកបានឯកភាពគ្នាដូចខាងក្រោម៖

-ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនផ្តល់ជូនប្រាក់ឧបត្ថម ចំនួន៥០%នៃប្រាក់ខែគោលនិង រួមនិងអត្ថប្រយោជន៍ផ្សេងៗ។ប្រាក់ឧបត្ថមនឹងត្រូវបើកជូននិយោជិកកម្មករជាពីរវគ្គដូចខាងក្រោម ៖

១. ប្រាក់ឧបត្ថមសំរាបការព្យួរការងារពីថ្ងៃទី២៣ ដល់៣០ ខែវិច្ឆិកា ឆ្នាំ២០២១នឹងត្រូវបើកជូននៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០២១។

២. ប្រាក់ឧបត្ថមសំរាបការព្យួរការងារពីថ្ងៃទី០១ ដល់១៣ ខែធ្នូ ឆ្នាំ២០២១នឹងត្រូវបើកជូននៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១។

ការពិភាក្សានេះបានបញ្ចប់នៅវេលាម៉ោង ០៩ និង ២០ នាទីព្រឹក នៅថ្ងៃខែឆ្នាំដដែល ដោយភាពរីករាយនិងស្មារតីយោគយល់គ្នា ហើយទទួលយកនូវកិច្ចព្រមព្រៀងនេះ។

កំពង់ចាម ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០២១

ហត្ថលេខា និង ត្រានាយក

<u>ប្រតិភូបុគ្គលិក</u>

MEDTECS(CAMBODIA)CORP LIMITED

Thomas TU